**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០១ ផក

# ផែនការ
# ស្តីពី
# យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៩
# រយៈពេល១ឆ្នាំ( ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

ផ្អែកតាមលទ្ធផល នៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់កន្លងមក យើងពិនិត្យឃើញថា កងកម្លាំងអនុវត្តច្បាប់ ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បានខិតខំប្រឹងប្រែងយ៉ាងសកម្មផុលផុស តស៊ូប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនយ៉ាងក្តៅគគុក ដូចភ្លៀងរលឹម ដោយទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ដូចតទៅ៖

- កម្ពុជាទទួលបានការគាំទ្រ និងកិច្ចសហការពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ជាពិសេសករណីធំៗ និងករណីកែច្នៃផលិតសារធាតុញៀន ត្រូវបានបង្ក្រាប និងកាត់បន្ថយស្ទើរតែគ្មានសកម្មភាពក្នុងឆ្នាំ២០២៣
- ការបន្តស្រាវជ្រាវ បង្ក្រាបបទល្មើសសម្អាតប្រាក់ដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដោយបានបង្កក រឹបអូសទ្រព្យសម្បត្តិពីក្រុមឧក្រិដ្ឋជនគ្រឿងញៀនបានយ៉ាងច្រើនសន្ធឹកសន្ធាប់ បានរួមចំណែកធ្វើឱ្យកម្ពុជាចាកចេញពីបញ្ជីប្រផេះនៃ FATF
- លទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ចំនួន៨លើកកន្លងទៅ (២០១៧-២០២៣) កងកម្លាំងអនុវត្តច្បាប់បានបើកប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន**៥៥.៣០៥ករណី** ឃាត់ខ្លួនជនសង្ស័យ **១២០.៣០៧នាក់** ចាប់យកសារធាតុញៀនគ្រប់ប្រភេទទម្ងន់ប្រមាណ**២៧.៦៤១គ.ក្រ** និងសារធាតុគីមីផ្សំប្រមាណ**៥២០.០០៥គ.ក្រ** រួមទាំងមធ្យោបាយ សម្ភារៈនិងវត្ថុតាងជាច្រើនទៀត។ ក្នុងនោះសមត្ថកិច្ចបានស្រាវជ្រាវ បានរកឃើញ និងបានបង្ក្រាប បទល្មើសគ្រឿងញៀនដែលមានអង្គការចាត់តាំងចំនួន**៤៣៥ករណី** ឃាត់ខ្លួនមេក្លោង**១៦៤នាក់** និងខ្សែរយៈបណ្តាញ**៨១១នាក់** ហើយបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់។

ទោះបីជាប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនខុសច្បាប់ ទទួលបានលទ្ធផលជាវិជ្ជមានដូចបានពោលខាងលើក្តី ផ្អែកតាមនិន្នាការថ្មីនៃការកែច្នៃផលិត ដឹកជញ្ជូន ជួញដូរសារធាតុញៀនជាសកល និងបញ្ហាថ្មីៗមួយចំនួនទៀត ត្រូវបានកត់សម្គាល់ក្នុងកិច្ចប្រតិបត្តិការបង្ក្រាបដូចជា៖ ការប្រើប្រាស់ល្បិចកលនាំចូលនូវសារធាតុគីមីបម្រើឱ្យវិស័យកសិកម្ម ឧស្សាហកម្ម បន្លំយកមកកែច្នៃផលិតជាសារធាតុញៀន គួបផ្សំ

និងការប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍ នៅតែជាបញ្ហាប្រឈមរ៉ាំរ៉ៃដែលត្រូវយកចិត្តទុកដាក់ចាត់វិធានការដោះស្រាយឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

ដោយពិនិត្យឃើញថា ហានិភ័យដែលបណ្តាលមកពីឧក្រិដ្ឋកម្មគ្រឿងញៀន នៅតែបន្តរីករាលដាលទាំងនៅក្នុងតំបន់និងលើពិភពលោក រួមទាំងនៅកម្ពុជាផងនោះ **រាជរដ្ឋាភិបាលកម្ពុជា** សម្រេចបន្តរៀបចំកសាង **ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៩ ឆ្នាំ២០២៤** ដើម្បីការពារកិត្តិយសកិត្យានុភាពជាតិ បញ្ចៀសឱ្យបាននូវភាពរងគ្រោះដោយសារឧក្រិដ្ឋកម្មគ្រឿងញៀន សំដៅធ្វើឱ្យបរិយាកាសសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមកាន់តែមានភាពល្អប្រសើរឡើងថែមទៀត ក៏ដូចជាការថែរក្សានូវសុខុមាលភាពសង្គម លើកកម្ពស់ការអភិវឌ្ឍធនធានយុវជន និងបង្កើនភាពកក់ក្តៅនៅក្នុងសង្គមគ្រួសាររបស់ប្រជាពលរដ្ឋ ដែលមានគោលការណ៍និងវិធានការ ដូចខាងក្រោម៖

## I. គោលការណ៍រួម

- បន្តចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបទបញ្ជាលេខ០១បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដោយខិតខំចាត់វិធានការបង្ការ ទប់ស្កាត់ និងបញ្ចៀសឱ្យបាន មិនឱ្យប្រទេសកម្ពុជាក្លាយជាគោលដៅនៃការប្រព្រឹត្តបទល្មើសគ្រឿងញៀន និងមិនឱ្យគ្រឿងញៀនបង្កឥទ្ធិពលញាំញី បំផ្លិចបំផ្លាញសង្គមជាតិ ជាពិសេសកិច្ចខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចនូវការប្តេជ្ញាចិត្តថា៖ **កម្ពុជាជាប្រទេសគ្មានគ្រឿងញៀន និងរក្សាគ្រួសារនីមួយៗ ជាគ្រួសារស្អាតស្អំ គ្មានគ្រឿងញៀន** តាមទស្សនវិស័យ **«ចូលរួមទាំងអស់គ្នាដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន»**

- អប់រំបំផុសចលនា លើកទឹកចិត្តឱ្យមានការចូលរួមច្រើនកុះករពីគ្រប់សមាសភាពនៃសង្គម សំដៅបង្កើតបានជាកម្លាំងសរុប មធ្យោបាយសរុប វិធានការសរុប ជាពិសេសស្រទាប់យុវជនក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ស្របតាមទិសស្លោក **«៣កុំ ១រាយការណ៍»**។ ទន្ទឹមគ្នានេះ ត្រូវជំរុញចលនាផ្សព្វផ្សាយគោលនយោបាយ **«ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព»** ឱ្យបានសកម្ម ផុលផុសតាមគ្រប់រូបភាព គ្រប់ទីកន្លែងចំគោលដៅ និងចំមុខសញ្ញា ជាពិសេសសិស្សានុសិស្ស កម្មករ ពលករ ដើម្បីបានជ្រួតជ្រាប យល់ដឹងអំពីគ្រោះថ្នាក់ដោយសារគ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្លើយបដិសេធចំពោះគ្រឿងញៀន និងឈានទៅលុបបំបាត់ទីផ្សារគ្រឿងញៀន

- រៀបចំប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (Hotline) ដើម្បីដាក់ឱ្យដំណើរការក្នុងការទទួលព័ត៌មាន និងចាត់វិធានការដោះស្រាយ និងអន្តរាគមន៍ នៅពេលមានបណ្តឹង ព័ត៌មាន ឬសំណូមពរពីមជ្ឈដ្ឋាននានាពាក់ព័ន្ធបទល្មើសគ្រឿងញៀន

- ជំរុញអនុវត្តវិធានការច្បាប់ និងវិធានការរដ្ឋបាលឱ្យបានម៉ឺងម៉ាត់ និងដួចភ្លៀងរលឹម សំដៅស្រាវជ្រាវរកឱ្យឃើញបណ្តាញអង្គការចាត់តាំងនៃក្រុមឧក្រិដ្ឋជនគ្រឿងញៀន ឧបាយកល សកម្មភាពទំនាក់ទំនងការដឹកជញ្ជូន កែច្នៃ ផលិត ជួញដូរគ្រឿងញៀន រួមទាំងទីតាំងប្រមូលផ្តុំការប្រើប្រាស់គ្រឿងញៀន ដើម្បីបើកប្រតិបត្តិការបង្ក្រាបឱ្យដល់ឫសគល់ប្រកបដោយប្រសិទ្ធភាព

- ពង្រឹង និងជំរុញយន្តការត្រួតពិនិត្យសារធាតុគីមីផ្សំឱ្យបានរឹងមាំ និងសកម្ម ក្នុងការទប់ស្កាត់ការលួចបង្វែរសារធាតុគីមីផ្សំ យកទៅធ្វើការកែច្នៃផលិតគ្រឿងញៀនខុសច្បាប់

- ខិតខំប្រមូលផ្តុំលើកកម្ពស់សមត្ថភាព លទ្ធភាពគ្រប់គ្រង ព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម អ្នកញៀនគ្រឿងញៀនឱ្យបានល្អប្រសើរថែមទៀត ដើម្បីទប់ស្កាត់ការរីករាលដាលការប្រើប្រាស់គ្រឿងញៀន និងឈានទៅលុបបំបាត់ទីផ្សារគ្រឿងញៀន សំដៅរួមចំណែកកាត់បន្ថយបទល្មើសផ្សេងៗ ដែលទទួលរង ឥទ្ធិពលពីគ្រឿងញៀន

- លើកកម្ពស់សមត្ថភាពបំពេញការងាររបស់មន្ត្រីអនុវត្តច្បាប់ទាំងលើវិស័យជំនាញ និងនីតិវិធី ព្រមទាំងត្រូវបង្កើតឱ្យមានកិច្ចសហការគ្នាល្អជាមួយស្ថាប័នអយ្យការ និងតុលាការ ដើម្បីរិះរកវិធីកសាង សំណុំរឿងរឹងមាំ ដើម្បីធ្វើការផ្តន្ទាទោសដល់ក្រុមឧក្រិដ្ឋជនគ្រឿងញៀនឱ្យបានម៉ឺងម៉ាត់តាមច្បាប់

- ពង្រឹង និងពង្រីកវិសាលភាពសហប្រតិបត្តិការឱ្យបានទូលំទូលាយ ជាមួយបណ្តាប្រទេសជាមិត្ត អង្គការជាតិ អន្តរជាតិ ស្ថាប័នអនុវត្តច្បាប់ បរទេសជាដៃគូ ដើម្បីបង្ការ ទប់ស្កាត់ពីចម្ងាយ និងទទួលព័ត៌មាន បម្រើឱ្យការបង្ក្រាប ព្រមទាំងធ្វើការដកបទពិសោធពីគ្នាទៅវិញទៅមក និងការជួយឧបត្ថម្ភ គាំទ្រទាំងស្មារតី និងសម្ភារ

- ខិតខំយកចិត្តទុកដាក់ពង្រឹងកិច្ចសហប្រតិបត្តិការស្រាវជ្រាវ បង្ក្រាបបទល្មើសសម្អាតប្រាក់ពាក់ព័ន្ធ គ្រឿងញៀនដើម្បីកាត់ផ្តាច់ចរន្តហិរញ្ញវត្ថុផ្គត់ផ្គង់ដល់សកម្មភាពរបស់ក្រុមឧក្រិដ្ឋជនគ្រឿងញៀន។

## II. ទិសដៅការងារ

### ១. ទិសដៅការអប់រំ

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីស្នូលក្នុងការផ្សព្វផ្សាយ អប់រំ តាមគ្រប់រូបភាព និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជារដ្ឋបាលរាជធានី ខេត្ត ក្នុង ការលើកកម្ពស់ ការយល់ដឹង និងការចូលរួមពីគ្រប់មជ្ឈដ្ឋានដូចជា៖

- សហការជាមួយក្រសួងព័ត៌មាន រៀបចំក្រុមការងារវេទិកាតុមូល ដើម្បីធ្វើការអប់រំខ្លឹមសារប្រយុទ្ធ ប្រឆាំងគ្រឿងញៀនតាមកម្មវិធីទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម និងត្រូវកំណត់ឱ្យស្ថានីយទូរទស្សន៍ ស្ថានីយវិទ្យុ និងបណ្តាញផ្សព្វផ្សាយព័ត៌មានសង្គម ត្រូវមានកម្មវិធីផ្សាយអំពីការអប់រំគ្រឿងញៀនជាក់លាក់ ឱ្យបានជាប្រចាំរាល់ថ្ងៃ

- ពិគ្រោះយោបល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹងនិងពង្រីកកម្មវិធីសិក្សា ព្រមទាំង សកម្មភាពអប់រំប្រឆាំងគ្រឿងញៀនជាប្រចាំ សម្រាប់ឱ្យសិស្សានុសិស្សរៀនសូត្រនៅតាមគ្រប់កម្រិត គ្រប់គ្រឹះស្ថានសិក្សា ស្របតាមកម្មវិធីនៃកម្រិតសិក្សានីមួយៗព្រមទាំងបញ្ចូលក្នុងកម្មវិធីប្រឡងផងដែរ

- ជំរុញឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំកម្មវិធីអប់រំប្រឆាំងគ្រឿងញៀនដល់ កម្មករ និងនិយោជិតនៅតាមរោងចក្រ សហគ្រាស សិប្បកម្ម និងការដ្ឋានសំណង់នានា

- ស្នើដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យធ្វើការណែនាំដល់ក្រុមហ៊ុនទូរស័ព្ទផ្ញើសារអប់រំ ប្រឆាំងគ្រឿងញៀន ដល់អ្នកប្រើប្រាស់ឱ្យបានញឹកញាប់ជាប់ជាប្រចាំ

- សហការជាមួយក្រសួងទេសចរណ៍ ដើម្បីកំណត់ឱ្យម្ចាស់ ឬអ្នកកាន់កាប់គ្រប់គ្រងគោលដៅដែល ពាក់ព័ន្ធនឹងវិស័យទេសចរណ៍ រួមទាំងកន្លែងកម្សាន្តសប្បាយនានា ដាក់តាំង បិតនូវខ្លឹមសារអប់រំ ឬការហាម ឃាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន

- សហការជាមួយសមាគមអ្នកនិពន្ធ សមាគមសិល្បករខ្មែរ ដើម្បីផលិតសារអប់រំខ្លី និងរៀបចំព្រឹត្តការណ៍ ផ្សព្វផ្សាយអប់រំអំពីគ្រឿងញៀនខុសច្បាប់ និងផលប៉ះពាល់ដោយសារគ្រឿងញៀន

- សំណូមពរដល់ក្រសួងធម្មការ និងសាសនា រៀបចំឱ្យមានកម្មវិធី ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំប្រឆាំងគ្រឿងញៀន តាមរយៈកម្មវិធីសាសនា និងការទេសនារបស់ព្រះសង្ឃជូនពុទ្ធបរិស័ទ

- ណែនាំ និងជំរុញគណៈបញ្ជាការឯកភាពរដ្ឋបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងក្រុមការងារថ្នាក់ជាតិគ្រប់ថ្នាក់ ត្រូវរៀបចំឱ្យមានព្រឹត្តិការណ៍ផ្សព្វផ្សាយអប់រំប្រឆាំងគ្រឿងញៀន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមួយកន្លែងឱ្យបានយ៉ាងតិច២លើកក្នុងមួយខែ តាមរយៈវេទិកាសាធារណៈ វេទិកាផ្សព្វផ្សាយគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" ឬវេទិកាផ្សេងៗទៀត។

**២. ទិដ្ឋានការរដ្ឋបាល**

២.១.គណៈបញ្ជាការឯកភាពរដ្ឋបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន៖

- ត្រូវរៀបចំបញ្ជី និងក្តាប់ឱ្យបាននូវគោលដៅដែលងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន និងត្រូវកោះអញ្ជើញម្ចាស់ទីតាំង ឬអ្នកកាន់កាប់គ្រប់គ្រងអាជីវកម្មទាំងនោះ មកធ្វើការពន្យល់ណែនាំឱ្យយកចិត្តទុកដាក់ក្នុងការងារគ្រប់គ្រងឱ្យបានហ្មត់ចត់ ព្រមទាំងធ្វើកិច្ចសន្យាសហការបង្ការ ទប់ស្កាត់មិនឱ្យកើតមានបទល្មើសគ្រឿងញៀននៅក្នុងទីតាំងរបស់ខ្លួន

- ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងចាត់វិធានការម៉ឺងម៉ាត់ ដាច់ខាត ដើម្បីបិទ ឬដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតធ្វើអាជីវកម្មជាបណ្តោះអាសន្ន ឬជាស្ថាពរចំពោះទីតាំងអាជីវកម្មណាដែលបណ្តែតបណ្តោយឱ្យមានសកម្មភាពជួញដូរ ឬប្រើប្រាស់គ្រឿងញៀន

- ត្រូវមានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ សហគមន៍ គ្រឹះស្ថានសិក្សា គ្រឹះស្ថានសាធារណៈ រោងចក្រ សហគ្រាស និងវិស័យឯកជននានា ដើម្បីមានវិធានការ និងមានកិច្ចសហការក្នុងការបង្ការ ទប់ស្កាត់បទល្មើសគ្រឿងញៀន ឬអនុវត្តវិធានការរដ្ឋបាល។

២.២.អគ្គនាយកដ្ឋានពន្ធនាគារ ត្រូវបន្តយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែឱ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ ប្រកបដោយស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់ ដោយមិនត្រូវឱ្យមានការលបលាក់ ឬនាំចូលសារធាតុញៀនផ្តល់ឱ្យពិរុទ្ធជន ឬទណ្ឌិត និង/ឬមានទំនាក់ទំនងពីក្នុងពន្ធនាគារចេញមកខាងក្រៅឬពីមជ្ឈដ្ឋានខាងក្រៅមកក្នុងពន្ធនាគារពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។ ជាមួយគ្នានេះ ត្រូវពិចារណាលើវិធានការគ្រប់គ្រងជនល្មើសដែលពាក់ព័ន្ធគ្រឿងញៀន ឬសេពគ្រឿងញៀន ដាច់ដោយឡែកពីទណ្ឌិត ឬពិរុទ្ធជនដទៃទៀត។

**៣. ទិដ្ឋានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម**

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកទឹកចិត្ត និងគាំទ្រ ជានានិរន្តរភាពនៃកិច្ចដំណើរការនៃមជ្ឈមណ្ឌលបណ្តោះអាសន្នសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅកងពលតូចថ្មើរជើងលេខ៣១ និងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ កែវ ផុស

- ក្រសួងសុខាភិបាល ត្រូវខិតខំលើកកម្ពស់សមត្ថភាព វិជ្ជាជីវៈក្នុងការបន្សាប និងព្យាបាល ព្រមទាំងពង្រីកសេវាបន្សាប ព្យាបាលដោយផ្អែកលើសហគមន៍នៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីចូលរួមចំណែកកាត់បន្ថយការរីករាលដាលនៃការប្រើប្រាស់គ្រឿងញៀននៅតាមមូលដ្ឋាន

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវពង្រឹង និងពង្រីកសមត្ថភាពមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទា របស់រដ្ឋបន្ថែមទៀត ដើម្បីត្រៀមទទួលជនរងគ្រោះ តាមការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ ក្នុងយុទ្ធនាការនេះ

- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់រៀបចំឱ្យមានយន្តការគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀន ដោយត្រូវប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ អំពីមុខសញ្ញាប្រើប្រាស់ និងងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន។ ទន្ទឹមគ្នានោះ ត្រូវជំរុញ និងលើកទឹកចិត្តអ្នកដែលមិនទាន់ទទួលបានការព្យាបាល ឱ្យទៅទទួលយកការព្យាបាល និងត្រូវចាត់វិធានការតាមដានគ្រប់គ្រងចំពោះបុគ្គល ដែលបានសមាហរណកម្មចូលក្នុងសហគមន៍ បន្ទាប់ពីចាកចេញពីមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ដើម្បីបង្ការ ទប់ស្កាត់កុំឱ្យវិលត្រឡប់ទៅសេពគ្រឿងញៀនវិញ

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវពិនិត្យលទ្ធភាព និងលើកសំណើដើម្បីបង្កើតនូវមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅមូលដ្ឋានរបស់ខ្លួន ជាពិសេសលើកទឹកចិត្តវិស័យឯកជន ដើម្បីចូលរួមក្នុងការគាំទ្រ ឬបង្កើតមជ្ឈមណ្ឌលសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសហការជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កលក្ខណសម្បត្តិលើកទឹកចិត្តដល់មណ្ឌលបណ្តោះអាសន្នឯកជន ដែលបន្សាប ព្យាបាលអ្នកញៀនគ្រឿងញៀន។

**៤. វិធានការអនុវត្តច្បាប់**

៤.១.គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំកម្លាំងអនុវត្តច្បាប់ និងកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការម៉ឺងម៉ាត់ក្នុងការស្វែងរកឱ្យឃើញ និងទប់ស្កាត់ការលួចលាក់នាំចូលគ្រឿងញៀនខុសច្បាប់ឆ្លងកាត់ព្រំដែន ចូលមកក្នុងភូមិសាស្ត្រខេត្តរបស់ខ្លួន ឬឆ្លងកាត់ពីខេត្តមួយទៅខេត្តមួយទៀត ដោយត្រូវយកចិត្តទុកដាក់៖

- ជំរុញការបើកករណីតស៊ូ ស្រាវជ្រាវ បង្ក្រាបមេខ្លោង និងបណ្តាញជួញដូរគ្រឿងញៀនឆ្លងដែន បញ្ជូនទៅតុលាការផ្តន្ទាទោសតាមច្បាប់ និងខិតខំស្រាវជ្រាវករណីសេសសល់ដែលមិនទាន់បានបញ្ចប់

- បើកយុទ្ធនាការជាប្រចាំបោសសម្អាតពួកជួញដូរគ្រឿងញៀនជាក្រុមតូចៗ ឱ្យបានម៉ឺងម៉ាត់ តឹងរឹងបំផុត និងអនុវត្តវិធានការច្បាប់

- បើកយុទ្ធនាការជាប្រចាំបោសសម្អាតអ្នកប្រើប្រាស់គ្រឿងញៀន តាមវិធីសហការជាមួយអាណាព្យាបាល សាលារៀន ឬសហគមន៍ ដើម្បីអប់រំ ព្យាបាលនៅតាមសហគមន៍ (ករណីស្រាល) ឬបញ្ជូនទៅមណ្ឌលបន្សាប ព្យាបាល និងស្តារនីតិសម្បទា (ករណីធ្ងន់ធ្ងរ) និងករណីចាំបាច់អនុវត្តវិធានការដាក់ទណ្ឌកម្មក្រោម**៤៨ម៉ោង** ដោយឱ្យធ្វើការងារហត្ថកម្ម ឬអនាម័យតាមទីសាធារណៈ

- តាមដាន គ្រប់គ្រង និងបង្ក្រាបឱ្យបានម៉ឺងម៉ាត់នូវសកម្មភាពកែច្នៃ ផលិតគ្រឿងញៀនសំយោគ ការដាំដុះ ការចម្រាញ់ ការនាំចូលវត្ថុធាតុដើមជាសារធាតុគីមីផ្សំដែលអាចកែច្នៃ ផលិតគ្រឿងញៀនសំយោគ ដែលកើតមាននៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ធ្វើជាអ្នកសម្របសម្រួល ដើម្បីជំរុញកិច្ចពិគ្រោះ ពិភាក្សារវាងស្ថាប័នអយ្យការ តុលាការ ជាមួយ អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ដើម្បីធ្វើឱ្យកិច្ចសហការ កាន់តែមានដំណើរការរលូន លុបបំបាត់និទណ្ឌភាព និងរិះរកវិធីកសាងសំណុំរឿងរឹងមាំ ដើម្បីធ្វើការផ្តន្ទាទោសដល់មេខ្លោង និងបណ្តាញជួញដូរគ្រឿងញៀនឱ្យបានម៉ឺងម៉ាត់ ស្របតាមច្បាប់។

៤.២.ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តជាប់ព្រំដែន ដែលមានការិយាល័យ BLO ត្រូវសហការជាមួយមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ រៀបចំកិច្ចប្រជុំត្រួតពិនិត្យក្នុងមួយខែម្តង ជាមួយប្រធាន និងមន្ត្រីការិយាល័យ BLO ដើម្បីជំរុញលើកទឹកចិត្តឱ្យមានកិច្ចសហការរួមគ្នា ក្នុងការផ្តល់ព័ត៌មាន និងផ្លាស់ប្តូរសភាពការណ៍ជាប់ជាប្រចាំ។

៤.៣.គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ត្រូវខិតខំសហការជាមួយភាគីឡាវ ដើម្បីផ្លាស់ប្តូរព័ត៌មាន និងសហការស៊ើបអង្កេតរកមុខសញ្ញា ឈានទៅបង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមព្រំដែន។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ**

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តបើកទូលាយកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយប្រទេសជិតខាង ក៏ដូចជាអង្គការអន្តរជាតិសំខាន់ៗ ដើម្បីផ្លាស់ប្តូរព័ត៌មានឱ្យបានទាន់ពេលវេលា និងនិន្នាការប្រែប្រួលនៃបញ្ហាគ្រឿងញៀនតាមដំណាក់កាលនីមួយៗ ក្តាប់បានអំពីខ្សែរយៈទំនាក់ទំនង និងបែបផែនសកម្មភាពរបស់ពួកឧក្រិដ្ឋជន គ្រឿងញៀន ដើម្បីម្ចាស់ការលើការវិធានការទប់ស្កាត់ពីចម្ងាយ និង/ឬធ្វើការបង្ក្រាបបានទាន់ពេល ក្នុងនោះ យកចិត្តទុកដាក់ទាំងកិច្ចសហប្រតិបត្តិការថ្នាក់ជំនាញ និងមន្ត្រី BLO ដែលឈរជើងតាមព្រំដែន

- អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវបើកទូលាយចំពោះកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន និង/ឬព័ត៌មានតាមករណីនីមួយៗ ជាមួយអង្គការ UNODC INTERPOL ជាមួយស្ថាប័នត្រួតពិនិត្យគ្រឿងញៀន និងស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសនានា ជាពិសេសបណ្តាប្រទេសដែលជាប្រភពនៃការនាំចូលគ្រឿងញៀនឆ្លងកាត់កម្ពុជា ដើម្បីមានវិធានការក្នុងការបង្ក្រាបអង្គការចាត់តាំង ឬបណ្តាញជួញដូរគ្រឿងញៀនជាអន្តរជាតិឱ្យដល់ឫសគល់។

III. **ការចាត់តាំងអនុវត្ត**

១. គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នេះដឹកនាំដោយ៖

- ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **ជាប្រធាន**

- ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជាអនុប្រធាន**។

២. យុទ្ធនាការនេះ ត្រូវមាន**គណៈកម្មការចម្រុះមួយ** ដើម្បីធ្វើជាយន្តការក្នុងការដឹកនាំ បញ្ជា និងចាត់តាំងអនុវត្ត និងត្រូវមាន**លេខាធិការដ្ឋានមួយ** ជាសេនាធិការ។

៣. ផ្អែកលើផែនការនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវកសាងផែនការសកម្មភាពជាក់ស្តែងតាមវិស័យនិងតាមភូមិសាស្ត្រនីមួយៗ សម្រាប់ចូលរួមអនុវត្តតាមតួនាទីភារកិច្ចរៀងៗខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

៤. ត្រូវមានវិធានការលើកសរសើរ ជូនរង្វាន់សមស្របរៀងរាល់ឆ្នាំដល់បណ្ដាអង្គភាព និងបុគ្គលដែលមានស្នាដៃល្អក្នុងការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន ព្រមទាំងមានវិធានការអនុវត្តវិន័យ ឬវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ចំពោះមន្ត្រី ដែលមានជាប់ពាក់ព័ន្ធបទល្មើសគ្រឿងញៀន។

ទទួលបានផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងគណៈអភិបាលរាជធានី ខេត្តទាំងអស់ ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់៕

ថ្ងៃព្រហស្បតិ៍ ១ កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**